*ប្រព័ន្ធការពារ និងតស៊ូមតិរបស់រដ្ឋកាលីហ្វ័រនីញ៉ា*
*លេខទូរស័ព្ទហៅមិនអស់ប្រាក់ (800) 776-5746*

# ជម្រើសដែលធ្វើឡើងដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់ ៖ សន្លឹកការពិតស្តីអំពី ផ្នែកដ៏សំខាន់មួយនៃដំណើរការស្តារនីតិសម្បទាវិជ្ជាជីវៈ

*ខែកុម្ភៈ ឆ្នាំ 2014 ឯកសារបោះពុម្ពផ្សាយលេខ 5540.06*

## 1. តើអ្វីជា "ជម្រើសដែលធ្វើឡើងដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់" ហើយហេតុអ្វីបានជាវាមានសារៈសំខាន់?

ច្បាប់សហព័ន្ធ តម្រូវឲ្យកម្មវិធី គម្រោង និងសកម្មភាពទាំងអស់ដែលទទួលថវិកាឧបត្ថម្ភ តាមរយៈច្បាប់ស្តារនីតិសម្បទា (Rehabilitation Act) បូករួមទាំងកម្មវិធីស្តារនីតិសម្បទាវិជ្ជាជីវៈរបស់រដ្ឋ ត្រូវតែ "អនុវត្តឡើងក្នុងស្ថានភាពដែលសម ស្របជាមួយនឹងគោលការណ៍នៃការគោរពភាពថ្លៃថ្នូរបស់មនុស្ស ការទទួលខុសត្រូវផ្ទាល់ខ្លួន ការប្តេជ្ញាចិត្តផ្ទាល់ខ្លួន និងការខិតខំប្រឹងរកការងារដែលមានន័យដោយអាស្រ័យលើជម្រើសដែលធ្វើឡើងដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់របស់បុគ្គលដែលមានពិការភាព" ។ ច្បាប់ Title 29 នៃក្រមសហរដ្ឋអាមេរិក (29 [USC, United States Code]) §701(c)(1) ។ សភាបានចែងថា គោល បំណងនៃសេវាកម្មទាំងអស់នេះ ត្រូវរួមបញ្ចូលនូវ "ការផ្តល់ជូនដល់ជនមាន ពិការភាពនូវឧបករណ៍ដែលចាំបាច់ ដើម្បី ... ធ្វើការជ្រើសរើស និងសម្រេចចិត្តដែលមានព័ត៌មានគ្រប់គ្រាន់ ហើយអាចសម្រេចបានឱកាសស្មើភាពគ្នា ទទួលបានការរាប់បញ្ចូល និងការធ្វើសមាហរណកម្មសង្គមពេញលេញ ការងារ ការរស់នៅដោយឯករាជ្យ ព្រមទាំងអាចពឹងពាក់ខ្លួនឯងបានទាំងផ្នែកសង្គមនិងសេដ្ឋកិច្ច  សម្រាប់បុគ្គលបែបនោះ" ។ 29 USC § 701(a)(6) ។

អ្នកដាក់ពាក្យ និងអតិថិជនរបស់នាយកដ្ឋានស្តារនីតិសម្បទា (DOR, Department of Rehabilitation) ត្រូវទទួលបានព័ត៌មាន និងសេវាកម្មគាំទ្រដើម្បីជួយដល់ពួកគេក្នុងការធ្វើការជ្រើសរើសដែលមានព័ត៌មានគ្រប់គ្រាន់ដែលគេហៅថាការធ្វើសេចក្តីសម្រេចប្រកបដោយអត្ថន័យ ឲ្យបានទូទាំងដំណើរការស្តារនីតិសម្បទា ។ ច្បាប់ Title 9 នៃក្រមបទបញ្ញត្តិកាលីហ្វ័រនីញ៉ា (CCR, California Code of Regulations) §7029.6(a) ។ ជម្រើសដែលធ្វើឡើងដោយមានព័ត៌មានគ្រប់គ្រាន់ ត្រូវតែផ្តល់ជូនដោយ DOR នៅក្នុងការអភិវឌ្ឍន៍ផែនការតម្រូវតាមលក្ខណៈបុគ្គលសម្រាប់ការងារ (IPE, Individualized Plan for

Employment) និងគោលបំណងការងាររបស់អ្នក ដើម្បីកំណត់អំពីសេវាកម្មជាក់លាក់របស់ DOR ដែលត្រូវការដើម្បី អាចសម្រេចបាននូវគោលបំណងការងាររបស់អ្នក អង្គភាពដែលជាអ្នកផ្តល់ជូនសេវាកម្មទាំងនោះ ទីកន្លែងផ្តល់សេវាកម្ម ព្រមទាំងវិធីសាស្រ្តដែលមានស្រាប់ សម្រាប់ទទួលយកសេវាកម្ម ។ 9 CCR § 7029.6(b)(4) ។ ជម្រើសដែលធ្វើឡើងដោយមានព័ត៌មានគ្រប់គ្រាន់ អាចមានរួមបញ្ចូលនូវការផ្តល់ព័ត៌មានដល់អតិថិជន ឬអ្នកដាក់ពាក្យ នៅក្នុងភាសា ឬរបៀបនៃការទំនាក់ទំនង ដែលសាម៉ីខ្លួនអាចយល់បាន ឬការផ្តល់ជូនសេវាកម្មគាំទ្រដល់មនុស្សដែលមានពិការភាពសតិបញ្ញា ។ 9 CCR § 7029.6(b)(1) ។

## 2. តើខ្ញុំអាចប្រើជម្រើសដែលធ្វើឡើងដោយមានព័ត៌មានគ្រប់គ្រាន់របស់ខ្ញុំយ៉ាងដូចម្តេច ក្នុងការជ្រើសរើសលទ្ធផលការងារ?

ក្នុងនាមជាអតិថិជនរបស់ DOR អ្នកមានសិទ្ធិធ្វើជា ដៃគូសកម្ម និងពេញលេញ ព្រមទាំងប្រើជម្រើសដែលមានព័ត៌មានគ្រប់គ្រាន់នៅទូទាំងដំណើរការទាំងមូល ចំពោះដំណើរការស្តារនីតិសម្បទាវិជ្ជាជីវៈ បូករួមទាំងការជ្រើសរើសគោល បំណងការងារ និងការរៀបចំបង្កើត IPE របស់អ្នក ។ 9 CCR § 7029.7(b)(1) និងច្បាប់ស្តារនីតិសម្បទា (Rehab. Act) § 120(b)(2)(B) ។ IPE មួយ ត្រូវបង្កើតឡើងដើម្បីអាចសម្រេចបាននូវលទ្ធផលការងារជាក់លាក់ នៅក្នុងស្ថានភាពសមាហរណកម្ម ដែលត្រូវបាន *ជ្រើសរើសដោយសាម៉ីខ្លួន* ហើយមានភាពស្របគ្នាជាមួយនឹងភាពខ្លាំងជាលក្ខណៈពិសេស ធនធាន អាទិភាព ក្តីបារម្ភ លទ្ធភាព សមត្ថភាព ចំណាប់អារម្មណ៍ និងជម្រើសដែលមានព័ត៌មានគ្រប់គ្រាន់របស់សាម៉ីខ្លួន ។ 9 CCR § 7128(d) ច្បាប់ Title 34 នៃក្រមបទបញ្ញត្តិសហព័ន្ធ (CFR , Code of Federal Regulation) § 361.45 ។ ដើម្បីវាយតម្លៃគោលបំណងរបស់អ្នក DOR អាចត្រូវការព័ត៌មានពាក់ព័ន្ធ នឹងសមត្ថភាពរបស់អ្នក ដែលព័ត៌មាននេះអាចទទួលបានតាមរយៈការវាយតម្លៃទូលំទូលាយ ឬក៏ DOR អាចបង្កើតនូវទិសដៅក្នុងរយៈពេលខ្លី ដាច់ៗពីគ្នា នៅក្នុង IPE ។ *សូមអាន* គោលនយោបាយរដ្ឋបាលសេវាកម្មស្តារនីតិសម្បទា (RSA, Rehabilitation Services Administration) លើសេចក្តីបង្គាប់លេខ 97-04 ។

## 3. តើខ្ញុំអាចទទួលបានព័ត៌មាន ដើម្បីជួយខ្ញុំក្នុងការជ្រើសរើសអង្គភាពដែលជាអ្នកផ្តល់សេវាកម្មដល់ខ្ញុំបានទេ?

អាចស្នើសុំបាន ។ DOR ត្រូវជួយអ្នក ក្នុងការរកព័ត៌មានដែលអាចជួយអ្នកក្នុងការជ្រើសរើសអង្គភាព ដែលនឹងផ្តល់សេវាកម្ម ដល់អ្នក ។ 9 CCR § 7029.6(b)(4) ។ DOR ត្រូវផ្តល់ ឬជួយអតិថិជន ក្នុងការរកព័ត៌មាន ដែលព័ត៌មានទាំងនោះមានដូចជា តែក៏មិនកំណត់តែចំពោះ ៖ តម្លៃ ការទទួលបានសេវាកម្ម និងរយៈពេលនៃសេវាកម្មដែលមានសក្តានុពល  ការពេញចិត្តរបស់អតិថិជន ចំពោះសេវាកម្មទាំងអស់នោះ (ក្នុងវិសាលភាពមួយដែលព័ត៌មាននេះ អាចរកបាន)

សមត្ថភាពតាមអ្វីជាភាពត្រូវរបស់អ្នកផ្តល់សេវាកម្មដែលមានសក្តានុពល ប្រភេទសេវាកម្ម ដែលផ្តល់ជូនដោយអ្នកផ្តល់សេវាកម្មដែលមានសក្តានុពល កម្រិតក្នុងការផ្តល់សេវាកម្ម នៅក្នុងស្ថានភាពសមាហរណកម្ម ព្រមទាំងលទ្ធផល ដែលសម្រេចបានដោយសាម៉ីខ្លួនដែលទទួលបានសេវាកម្មពីអ្នកផ្តល់សេវា ក្នុង វិសាលភាពមួយដែលព័ត៌មាននេះ អាចមានក្នុងការផ្តល់ជូន ។ 9 CCR §7029.6(d)។

អ្នកត្រូវស្នើសុំព័ត៌មានខាងលើ ស្តីអំពីអ្នកលក់ ឬអ្នកផ្តល់សេវាកម្ម ដែលណែនាំដោយ DOR ។ អ្នកក៏គួរតែស្នើសុំផងដែរ ឲ្យ DOR ផ្តល់ឲ្យអ្នកនូវជម្រើសមួយចំនួនអំពីអ្នកផ្តល់សេវាកម្ម សម្រាប់ធ្វើការជ្រើសរើស ។

## 4. តើខ្ញុំអាចជ្រើសរើសស្ថានភាពទីកន្លែងការងារ និងស្ថានភាពទីកន្លែងសម្រាប់ផ្តល់សេវាកម្មដែរឬទេ?

អាចស្នើសុំបាន ។ DOR អាចជួយអតិថិជនឲ្យទទួលបានការងារ ទៅតាមស្ថានភាពទីកន្លែងផ្សេងៗគ្នា ។ IPE របស់អ្នក ត្រូវតែរៀបចំឡើង ដើម្បីជួយ អ្នកឲ្យអាចសម្រេចបាននូវលទ្ធផលការងារជាក់លាក់ នៅក្នុងស្ថានភាពទីកន្លែង សមាហរណកម្ម ។ 9 CCR § 7128(d) ។ ស្ថានភាពសមាហរណកម្ម គឺអាចមាន នៅតាមសហគមន៍ ហើយជាទីកន្លែង ដែលជនមានពិការភាពអាចប្រាស្រ័យទាក់ទងជាមួយនឹងមនុស្សមិនមានពិការភាព ជាជាងឲ្យជនមិនមានពិការភាព ជាអ្នកផ្តល់សេវាកម្មដល់ជនមានពិការភាព ។ 9 CCR § 7018.4(a) ។

ចំពោះករណីមួយចំនួន DOR ក៏អាចជួយដល់ជនមានពិការភាព ឲ្យទទួលបានការងារលើសពីអ្វីដែលមានក្នុងផែនការ ដែលអតិថិជនធ្វើការក្នុងបរិបទដែលមិនមានសមាហរណកម្ម ឬនៅក្នុងទីកន្លែងបណ្តោះអាសន្ន និងជាជំហានអន្តរកាលក្នុងដំណើរការស្តានីតិសម្បទា ដើម្បីរៀបចំជនមានពិការភាពឲ្យអាចធ្វើការបានក្នុងស្ថានភាពដែលមានសមាហរណកម្ម ។ ការងារដែលលើសពីអ្វីដែលមានក្នុងផែនការ គឺមិនមែនជាចំណុចចុងបញ្ចប់ នៅក្នុងដំណើរការស្តានីតិសម្បទាឡើយ ហើយក៏មិនត្រូវបានចាត់ទុកថាជាលទ្ធផលការងារដែរ ។ 9 CCR វគ្គទី 7013.6 ។ បើ DOR ខកខានផ្តល់ឱកាសការងារ សេវាកម្ម និងលទ្ធផលការងារផ្សេង ក្នុងស្ថានភាពសមាហរណកម្ម អ្នកត្រូវហៅទូរស័ព្ទមកកាន់កម្មវិធីជំនួយអតិថិជន (CAP, Client Assistance Program) ។

បន្ថែមលើសពីការធ្វើសមាហរណកម្មកន្លែងការងារសាធារណៈ ឬកន្លែងឯកជន ស្ថានភាពកន្លែងការងារ អាចរួមបញ្ចូលនូវអ្វីដែលគាំទ្រការងារ មុខរបរផ្ទាល់ខ្លួន ឬភាពជាកម្មសិទ្ធិលើអាជីវកម្ម ។ អ្នកក៏អាចជ្រើសរើសធ្វើការពេញម៉ោង ឬមិនពេញម៉ោងបានដែរ ។ លទ្ធផលការងារនៃមេផ្ទះ និងអ្នកធ្វើការក្នុងគ្រួសារ ដែលមិនបានទទួលប្រាក់កម្រៃ គឺមាននៅក្នុងសហគមន៍ គឺត្រូវបានចាត់ទុកថាជាអ្វី

ដែលកើតមានឡើងក្នុងស្ថានភាពការងារដែលមានលក្ខណៈសមាហរណកម្ម ហើយមានភាពត្រឹមត្រូវចំពោះនិយមន័យនៃលទ្ធផលការងារ ចំពោះស្ថានការណ៍ណាមួយ ។ 9 CCR វគ្គទី 7011 ។ បើអ្នកជ្រើសរើសស្ថានភាពការងារជាមេ ផ្ទះ គឺវាត្រូវជាការងារដែលអ្នកអាចសង្ឃឹមថានឹងទទួលបានអត្ថប្រយោជន៍ ទាំងផ្នែកសេដ្ឋកិច្ច និងសង្គម ក្នុងចំណោមលក្ខណៈវិនិច្ឆ័យផ្សេងៗទៀត ។ 9 CCR វគ្គទី 7136 ។ បើអ្នកមិនយល់ស្រប ឬមិនបានជ្រើសយកការងារជា មេផ្ទះ/អ្នកធ្វើការក្នុងគ្រួសារដែលមិនទទួលបានកម្រៃ ជាគោលបំណងវិជ្ជាជីវៈទេ អ្នកត្រូវប្រាប់អ្នកប្រឹក្សាយោបល់ផ្នែកស្តារនីតិសម្បទារបស់អ្នកឲ្យបានដឹងថា អ្នកចង់ប្តូរគោលបំណងរបស់អ្នក ហើយសូមហៅទូរស័ព្ទមកជួប CAP ប្រសិនបើ DOR មិនយល់ព្រមប្តូរគោលបំណងរបស់អ្នកទេនោះ ។

## 5. តើត្រូវធ្វើដូចម្តេច បើខ្ញុំយល់ឃើញថា គេមិនបានផ្តល់ឲ្យខ្ញុំនូវជម្រើសប្រកបដោយព័ត៌មានគ្រប់គ្រាន់ ក្នុងដំណើរការស្តារនីតិសម្បទាវិជ្ជាជីវៈ ទេនោះ?

បើអ្នកយល់ឃើញថា គេមិនបានផ្តល់ឲ្យអ្នកនូវជម្រើសប្រកបដោយព័ត៌មានគ្រប់គ្រាន់ នៅដំណាក់កាលណាមួយក្នុងដំណើរការស្តារនីតិសម្បទាវិជ្ជាជីវៈ ទេនោះ អ្នកត្រូវសួរនាំអ្នកប្រឹក្សាយោបល់ និង/ឬអ្នកគ្រប់គ្រងរបស់ DOR ដើម្បី ព្យាយាមរកវិធីដោះស្រាយវិវាទ ឬស្វែងរកព័ត៌មាន ដើម្បីជួយអ្នក ក្នុងការធ្វើការសម្រេចចិត្តប្រកបដោយអត្ថន័យ អំពីសេវាកម្ម និងកម្មវិធីស្តារនីតិសម្បទារបស់អ្នក ។ អ្នកក៏មានសិទ្ធិទទួលបាន សិទ្ធិស្នើសុំឲ្យមានការរកដំណោះស្រាយតាមបែបរដ្ឋបាលជាមួយនឹងរដ្ឋបាលឌីស្រ្ទីក ព្រមទាំងសិទ្ធិស្នើសុំការសម្រុះ សម្រួល និង/ឬសវនាការយុត្តិធម៌ ផងដែរ ។

**បើអ្នកត្រូវការជំនួយក្នុងការដោះស្រាយវិវាទជាមួយនឹង DOR អ្នកអាចទាក់ទងមកកាន់កម្មវិធីជំនួយអតិថិជន តាមលេខ (800) 776-5746 ។**

*Disability Rights California បានទទួលថវិកាឧបត្ថម្ភពីប្រភពផ្តល់ជំនួយមួយចំនួន ។ សម្រាប់បញ្ជីលម្អិតនៃអ្នកផ្តល់ជំនួយ សូមទស្សនាគេហទំព័រ [http://www.disabilityrightsca.org/Documents/ListofGrantsAndContracts.html](http://www.disabilityrightsca.org/Documents/ListofGrantsAndContracts.html) ។*